ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តពោធិ៍សាត់

ស្រុកក្រគរ

រដ្ឋបាលឃុំត្នោតជុំ

លេខ: ០៩៤ /រដ្ឋ ត.ជ

សេចក្តីប្រកាស

ស្តីពីការចប់ស្កាត់ និងការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង

យោងស្មារតីអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ កាលពីថ្ងៃទី ២៦ ខែ ឆ្នូ ឆ្នាំ ២០២១ បានឯកភាពនិងអនុម័តដាក់ចេញនៅសេចក្តីប្រកាសស្តីពីការចប់ស្កាត់និងកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំត្នោតជុំទាំងមូល មានគោលបំណងប្រាំមួយចំណុចដូចខាងក្រោម

១.លើកស្ទួយសុខមាលភាពប្រជាពលរដ្ឋ

២.ធ្វើឲ្យមានសុភមង្គលក្នុងគ្រួសារ

៣.ធ្វើឲ្យសង្គមជាតិមានការរីកចម្រើន

៤.កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍

៥.លើកស្ទួយជីវភាពប្រជាពលរដ្ឋក្នុងមូលដ្ឋាន

៦.ជួយកាត់បន្ថយភាពក្រីក្រ។

ដើម្បីធានាបានអំពីគោលបំណងទាំងប្រាំមួយចំណុចខាងលើអង្គប្រជុំបានសម្រេចចេញសេចក្តីណែនាំដូចខាងក្រោម

១.មិនអនុញ្ញាតឲ្យជនណាម្នាក់លក់ និងផឹកគ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងវត្តអារាមគ្រប់ប្រភេទជាដាច់ខាត

២.ហាមផឹកស្រវឹងជជែកឡូឡាឈ្លោះប្រកែកគ្នាជុំគ្នាច្រៀងរាំចាក់ធុងបាស់ ឬ រំខានពេលសំរាករបស់អ្នកជិតខាង

៣.ហាមជេ គៀគរប្រមូល ឬ បង្ខំអ្នកដទៃឲ្យផឹកគ្រឿងស្រវឹង

៤.ហាមយកកំប៉ុងស្រាបៀរដាក់ជើងធូបសក្ការៈបូជាតាមផ្ទះ ឬតាមវត្តអារាម។

៥.ចំពោះអ្នកពិសារគ្រឿងស្រវឹង ត្រូវពិសារតាមកម្រិតច្បាប់ចរាចរណ៍ផ្លូវគោកបានកំណត់។

សេចក្តីណែនាំនេះត្រូវបានយកទៅផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឲ្យបានទូលំទូលាយដើម្បីជាប្រយោជន៍សំខាន់សម្រាប់អ្នកប្រើប្រាស់គ្រឿងស្រវឹង និងមានសុពលភាពចាប់ថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ភក្តី ១៣ ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

ត្រូវនឹងថ្ងៃទី ២៥ ខែ ក្រ ឆ្នាំ ២០២១

ស្នងការ

ជាប់ សុខឿន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តពោធិ៍សាត់

ស្រុកក្រគរ

រដ្ឋបាលឃុំស្ពោតជុំ

លេខ..ព្រ.ស.ឃ.ស្ព.ជ/...

ដីការ

ស្តីពី

ការបង្ការ និង ទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់។
- បានឃើញអនុក្រឹត្យលេខ ២២អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការ អំណាច តួនាទី និង ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ/សង្កាត់។
- យោងសៀវភៅឯកសារបច្ចេកទេសស្តីពីការបង្ការនិងទប់ស្កាត់គ្រឿងស្រវឹងសម្រាប់រដ្ឋបាលឃុំ/សង្កាត់របស់ក្រសួងមហាផ្ទៃលេខ ០២ស.ស.រ/គ.ជ.អ.ប ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧។
- យោងកិច្ចប្រជុំកាលពី ថ្ងៃទី..ខែ..ឆ្នាំ២០២១របស់ក្រុមប្រឹក្សាឃុំស្ពោតជុំ ស្តីពីការបង្ការ និងកាត់បន្ថយផល់បះពាល់នៃគ្រឿងស្រវឹងក្នុងឃុំស្ពោតជុំ
- យោងតាមតំរូវការចាំបាច់របស់រដ្ឋាលឃុំ ដោយយល់ឃើញថាបញ្ហាដែលបង្ករឡើងពីអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥតសណ្តាប់ធ្នាប់ ភាពក្រីក្រ និងប៉ះពាល់ដល់សុខភាពជារួមរបស់ប្រជាពលរដ្ឋក្នុងឃុំស្ពោតជុំ។

សម្រេច

ប្រការ ១:

ប្រការនេះមានគោលបំណងការពារសិទ្ធិស្ត្រី សិទ្ធិកុមារ និងបង្ការអំពើហិង្សា ព្រមទាំងលើកកម្ពស់សុខមាលភាពនិងប្រាក់ចំណូលប្រជាពលរដ្ឋ ក៏ដូចជារក្សាសន្តិសុខសណ្តាប់ធ្នាប់ក្នុងឃុំស្ពោតជុំទាំងមូល។

ប្រការ ២:

ដីការមានវិសាលភាពអនុវត្តទៅលើអ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា ឬបង្កការរំខាន បង្កអំពើហិង្សានានា ព្រមទាំងការលក់ផលិតផលគ្រឿងស្រវឹងទៅឲ្យជនទាំងឡាយណា ឬទីកន្លែងមួយចំនួនក្នុងឃុំស្ពោតជុំដែលមានចែងក្នុងប្រការនេះ។

ប្រការ ៣:

មេភូមិគ្រប់ភូមិ ក្រុមប្រឹក្សាឃុំ ព្រះចៅអធិការវត្ត ព្រះសង្ឃ សហគមន៍ នាយកសាលា មណ្ឌលសុខភាព និង សមាជិកគ្រួសារត្រូវបង្កើតការផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងទៅដល់ប្រជាពលរដ្ឋក្នុងឃុំ ឲ្យបានទូលំទូលាយ។

ក្នុងនោះត្រូវមានការណែនាំអ្នកប្រើប្រាស់គ្រឿងស្រវឹងជាប្រចាំ ឲ្យពួកគាត់កាត់បន្ថយ និងធ្វើការងារ ក៏ដូចជាលេងកីឡាផ្សេងៗ ឲ្យបានបានច្រើន។ ករណីអ្នកស្រវឹងបង្កបញ្ហា ត្រូវរាការណ៍ជូនសមត្ថកិច្ច

ដើម្បីមានវិធានការណ៍តាមផ្លូវច្បាប់។

ប្រការ ៤:

ហាមក្មេងក្រោមអាយុ ១៨ឆ្នាំផឹកគ្រឿងស្រវឹង និងមិនត្រូវលក់គ្រឿងស្រវឹងឲ្យក្មេងក្រោមអាយុ១៨ឆ្នាំនៅឡើយ។ ជនគ្រប់រូបមិនត្រូវប្រើក្មេងក្រោមអាយុ១៨ទៅទិញគ្រឿងស្រវឹងនោះទេ។

ប្រការ ៥:

ហាមលក់ និងផឹកគ្រឿងស្រវឹងក្នុងវត្តអារាម គ្រឹះស្ថានសាសនា សាលារៀន សាលាឃុំ ប៉ុស្តិ៍រដ្ឋបាលឃុំ មណ្ឌលសុភាព ស្នាក់ការភូមិ និងអគារសាធារណៈនានា។

ប្រការ ៦:

ហាមលើកផ្ទាំងពាណិជ្ជកម្ម គ្រប់ប្រភេទ នៅផ្នែកខាងក្នុងនិងខាងក្រៅវត្តអារាម គ្រឹះស្ថានសាសនា សាលារៀន សាលាឃុំ ប៉ុស្តិ៍រដ្ឋបាលឃុំ មណ្ឌលសុភាព ស្នាក់ការភូមិ និងអគារសាធារណៈនានា។

ប្រការ ៧:

ហាមជនគ្រប់រូបប្រើប្រាស់គ្រឿងស្រវឹងហើយឡូឡាឬប្រើម៉ូតូឡានដែលមានសម្លេងរំខាន(កែឆ្នៃខុសបច្ចេកទេសដើម)ឬប្រើឧបករណ៍បំពងសំឡេងផ្សេងៗ ដែលបង្កការរំខានដល់អ្នកដទៃ ចាប់ពីម៉ោង១០ដល់ម៉ោង៦ព្រឹក។

ប្រការ ៨:

ជនណាដែលល្មើសនិងប្រការ ៤,៥,៦ និងប្រការ៧ ដូចដែលបានចែងខាងលើនេះត្រូវធ្វើការណែនាំលើកទី១ ដោយផ្ទាល់មាត់ និងលើកទី២ជាលាយលក់អក្សរ និងលើកទី ៣ ។ក្នុងករណី៣លើកមិនរាងចាល

អាជ្ញាធរឃុំ ឬនិងនគរបាលប៉ុស្តិ៍ត្រូវពិន័យជាសាច់ប្រាក់ចាប់ពី ២,0000រៀល (ពីរម៉ឺនរៀល) ដល់ ១00000រៀល (ដប់ម៉ឺនរៀល)។

ប្រការ ៩:

ថវិការដែលទទួលបានពីការពិន័យត្រូវដាក់បញ្ចូលជាថវិការមូលនិធិសម្រាប់ជូនកុមារកំព្រានិងចាស់ជរា ឥតទីពឹង ដែលមានទីលំនៅក្នុងឃុំឆ្នោតជុំ។

ប្រការ ១0:

ឃុំត្រូវបង្កើតគណកម្មការ និងជនបង្គោលស្ម័គ្រចិត្តតាមភូមិ សម្រាប់ជួយផ្សព្វផ្សាយឲ្យមានប្រសិទ្ធិភាពនិងការអនុវត្តន៍ដីការឃុំ បន្ទាប់ពីបានអនុម័តឲ្យប្រើប្រាស់ជាផ្លូវការ។

ប្រការ ១១:

ឃុំនិងត្រូវដាក់បញ្ចូលកម្មវិធីអប់រំផ្សព្វផ្សាយផលប៉ះពាល់ស្តីពីការប្រើប្រាសគ្រឿងស្រវឹង និងការធ្វើសកម្មភាពផ្សព្វផ្សាយទៅក្នុងផែនការអភិវឌ្ឍរបស់ឃុំសម្រាប់ធ្វើសកម្មភាពផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅតាមភូមិនិមួយៗក្នុងឃុំត្នោតជុំ។

ប្រការ ១២:

អាជ្ញាធរមូលដ្ឋាន(មេឃុំក្រុមប្រឹក្សាឃុំ មេភូមិ នគបាលប៉ុស្តិ៍រដ្ឋបាលឃុំ) មណ្ឌលសុភាព ព្រះសង្ឃ គ្រូបង្រៀន និងសហគមន៍ធ្វើការផ្សព្វផ្សាយដីការនេះជូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានឲ្យបានទូលទូលាយ។

ប្រការ ១៣:

ដីការមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ ឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

ត្រូវនឹងថ្ងៃទី ២៦ ខែ ១១ ឆ្នាំ ២០២១

ចម្លងជូន

- រដ្ឋបាលខេត្តពោធិ៍សាត់
- រដ្ឋបាលស្រុកក្រគរ
- អធិការដ្ឋាននគបាលស្រុកក្រគរ
  « គោរពជូនជ្រាប »
- ឯសារ កាលប្បវត្តិ